**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី**
**នៃព្រះរាជាណាចក្រកម្ពុជា**
**ថ្លែងក្នុង**
**ពិធីបិទសន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡា**
**ឆ្នាំសិក្សា ២០២៣-២០២៤ និងទិសដៅសម្រាប់ឆ្នាំសិក្សា ២០២៤-២០២៥**
វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា, ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៥

- ឯកឧត្តម លោកជំទាវ គណៈអធិបតី
- ឯកឧត្តម លោកជំទាវ លោក លោកស្រី
- សមាជិក សមាជិកាអង្គសន្និបាត ជាទីមេត្រី !

ថ្ងៃនេះ ខ្ញុំមានសេចក្តីរីករាយ ដែលបានចូលរួមក្នុង **«ពិធីបិទសន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា ២០២៣-២០២៤ និងលើកទិសដៅការងារឆ្នាំសិក្សា ២០២៤-២០២៥»** បន្ទាប់ពីបានដំណើរការដោយរលូនអស់រយៈពេល ៣ថ្ងៃកន្លងមកនេះ ក្នុងគោលដៅដាក់ចេញនូវវិធានការសម្រាប់បន្តអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡានាឆ្នាំសិក្សាបន្តបន្ទាប់ ជាពិសេសការចូលរួមគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលអាណត្តិទី៧នៃរដ្ឋសភា ក៏ដូចជាអនុសាសន៍ទាំង ៤ ចំណុច ដែលខ្ញុំបានដាក់ចេញនៅក្នុងអង្គប្រជុំលើកដំបូងនៃគណៈរដ្ឋមន្ត្រី ឆ្ពោះទៅលើកកម្ពស់គុណភាពអប់រំនៅតាមសាលារៀនសាធារណៈចាប់ពីថ្នាក់មត្តេយ្យសិក្សា ដល់មធ្យមសិក្សា រួមមាន៖ ទី១. ការពង្រឹងអភិបាលកិច្ចសាលារៀន, ទី២. ការពិនិត្យកែសម្រួល និងរៀបចំកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សាឱ្យស្របទៅតាម តម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់សិស្ស, ទី៣. ការយកចិត្តទុកដាក់លើសុខភាពរបស់សិស្ស តាមរយៈកម្មវិធីអាហារូបត្ថម្ភដល់កុមារ និងការត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលា, និងទី៤. ការជំរុញ និងលើកទឹកចិត្តការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ ក្នុងការអប់រំស្របតាមពាក្យស្លោកភាពជាដៃគូ រដ្ឋ និងសហគមន៍ដើម្បីការអប់រំ។

ខ្ញុំសូមកោតសរសើរដល់ថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់នៃក្រសួងអប់រំ យុវជន និងកីឡា ដែលបានតាត់ចែងអនុវត្តប្រកបដោយស្មារតីបុរេសកម្ម ក្នុងការពិនិត្យឡើងវិញលើស្តង់ដាសាលារៀនគំរូ រៀបចំយន្តការចុះជួយគាំទ្រនិងបង្វឹកសាលារៀន យន្តការចុះវាយតម្លៃសាលារៀន និងយន្តការពិនិត្យតាមដាន ជាពិសេសការធ្វើអាទិភាវូបនីយកម្មថវិកា និងប្រមូលផ្តុំធនធានសម្រាប់គាំទ្រដល់ការអនុវត្តស្តង់ដាសាលារៀនគំរូ ផងដែរ។ ខ្ញុំក៏សូមកោតសរសើរដល់លេខាធិការដ្ឋាននៃគណៈកម្មការជាតិជំរុញការអនុវត្តកំណែទម្រង់វិស័យអប់រំ (គវអ) ដែលបានជ្រើសរើសសាលាបឋមសិក្សា អនុវត្តវិធានការគន្លឹះ គវអ. នៅឆ្នាំទី១ និងបានពង្រីកវិសាលភាពជាបន្តបន្ទាប់ តាមយុទ្ធសាស្ត្រផ្ការីក។

**អង្គពិធីទាំងមូល ជាទីរាប់អាន!**

ទិសដៅអាទិភាពរបស់រាជរដ្ឋាភិបាលនៃរដ្ឋសភាអាណត្តិទី៧គឺ សាលារៀន ដែលជាអង្គភាពផ្តល់សេវាសាធារណៈនៅជិតប្រជាពលរដ្ឋ និងមានការកិច្ចប្រកបដោយការទទួលខុសត្រូវខ្ពស់ក្នុងការផ្តល់នូវវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដល់សិស្សានុសិស្សគ្រប់រូប។ ប្រការនេះទាមទារឱ្យសាលារៀនត្រូវពង្រឹងអភិបាលកិច្ចប្រកបដោយភាពធន់ បុរេសកម្ម និងការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ជាពិសេសសហគមន៍ និងមាតាបិតា ក្នុងការអភិវឌ្ឍសាលារៀន គ្រប់ជ្រុងជ្រោយស្របតាមស្តង់ដាសាលារៀនគំរូ ។

ខ្ញុំពិតជាគាំទ្រចំពោះការវាយតម្លៃសាលារៀនទាំងបីកម្រិត ដែលក្រសួងបានជ្រើសរើស និងទទួលស្គាល់ជាសាលារៀនគំរូ ទាំង១២០សាលា នៅដំណាក់កាលដំបូង និងនៅក្នុងឆ្នាំសិក្សាថ្មីនេះ យើងប្រកាសទទួលស្គាល់សាលារៀនគំរូចំនួន ១៤៤ បន្ថែមទៀត ដែលជាការទទួលស្គាល់នូវសមិទ្ធផលក្នុងការកែលម្អសាលារៀន ទាំងលទ្ធផលសិក្សារបស់សិស្ស ទាំងកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន សិស្សានុសិស្ស និងគ្រួសារសហគមន៍ក្នុងការអភិវឌ្ឍសាលារៀន។ ការទទួលស្គាល់នេះ ក៏ជាផ្សព្វផ្សាយនូវការប្រតិបត្តិដ៏ល្អ ដែលអាចជាគំរូដល់សាលារៀននៅជុំវិញ និងសាលារៀនដទៃទៀត ឱ្យខិតខំអភិវឌ្ឍសាលារៀន ផងដែរស្របតាមយុទ្ធសាស្ត្រផ្ការីក។

ជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំ និងបានបង្កើតលេខាធិការដ្ឋានមួយ ដែលដើរតួជាសេនាធិការរបស់គណៈកម្មាធិការជាតិ ក្នុងគោលបំណងជួយគាំទ្រដល់ការលើកកម្ពស់ការអប់រំ ដែលក្នុងដំណាក់កាលដំបូងផ្តោតលើសាលាបឋមសិក្សា ដោយផ្តោតលើការអប់រំចរិយាធម៌ និងការរៀបចំអនុវត្តកម្មវិធីក្រៅម៉ោងសិក្សាយ៉ាងហោច ២ម៉ោងសិក្សាបន្ថែម ដើម្បីឱ្យសិស្សបានមកសាលា

ាននូវការបំប៉នមេរៀនបន្ថែមទៅលើការសិក្សាក្នុងម៉ោងផ្លូវការ ដូចជា ការសិក្សា ... កុំព្យូទ័រ និងសកម្មភាពផ្សេងៗទៀតដូចជា ការអានជាក្រុម ការអាននៅក្នុងបណ្ណាល័យ ការធ្វើលំហាត់បន្ថែម សកម្មភាពសង្គម ការអប់រំសីលធម៌ និងការលេងកីឡា ។ល។ ការរៀបចំសកម្មភាពក្រៅម៉ោងសិក្សានេះ ក៏មានគោលដៅកាត់បន្ថយម៉ោងទំនេរ និងប្រែក្លាយម៉ោងទំនេររបស់កុមារ និងយុវជន ដែលអាចយកទៅប្រព្រឹត្តសកម្មភាពអសកម្មមួយចំនួនណានោះ ឱ្យក្លាយទៅជាម៉ោងសម្រាប់ការអភិវឌ្ឍសមត្ថភាពរបស់ខ្លួនវិញ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ វិស័យអប់រំបានឆ្លងកាត់ការធ្វើកំណែទម្រង់យ៉ាងស៊ីជម្រៅជាពិសេសបន្ទាប់ពីកំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ក្នុងឆ្នាំ២០១៣ និងសម្រេចបាននូវសមិទ្ធផលនានា ដូចបានលើកឡើងនៅក្នុងរបាយការណ៍សង្ខេបរបស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** ដែលពិតជាបានស្តែងចេញនូវកិច្ចខិតខំប្រឹងប្រែង និងកិច្ចសហការយ៉ាងស្អិតរមួតរបស់ថ្នាក់ដឹកនាំ, បុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់, លោកគ្រូ អ្នកគ្រូ, មាតាបិតា, សហគមន៍ និងអាជ្ញាធរដែនដី ក្នុងការអភិវឌ្ឍវិស័យអប់រំឱ្យមានការរីកចម្រើនទៅមុខ ស្របតាមតួនាទី និងភារកិច្ចរៀងៗខ្លួនជាមួយនឹងស្មារតីទទួលខុសត្រូវខ្ពស់។ ជាមួយនេះ ខ្ញុំក៏សូមអរគុណ និងវាយតម្លៃខ្ពស់ចំពោះដៃគូអភិវឌ្ឍ, អង្គការជាតិ អន្តរជាតិ, និងស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានចូលរួម, សហការ, និងផ្តល់ការឧបត្ថម្ភគាំទ្រទាំងសម្ភារៈ, ថវិកា, និងបច្ចេកទេស។

អង្គសន្និបាតអប់រំប្រចាំឆ្នាំនៅពេលនេះបានដំណើរការដោយរលូន ដោយបានបង្ហាញនូវសមិទ្ធផលជាច្រើនគួរជាទីមោទនៈលើការងារអប់រំ, ការអភិវឌ្ឍយុវជន, និងការអប់រំកាយនិងកីឡា និងបានពិនិត្យឡើងវិញនូវបញ្ហាប្រឈមនានា ព្រមទាំងបានដាក់ចេញនូវអាទិភាព និងទិសដៅការងារនាពេលខាងមុខ ឱ្យកាន់តែស៊ីជម្រៅ និងមុតស្រួច ស្របតាមបរិការណ៍ថ្មីៗនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចទាំងក្នុងតំបន់ និងពិភពលោក ជាពិសេសក្នុងខណៈ ដែលកម្ពុជាកំពុងរក្សាបាននូវសុខសន្តិភាពពេញលេញ, ស្ថិរភាពនយោបាយ, និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងបានឆ្លើយតបទៅនឹងចក្ខុវិស័យកម្ពុជានៅឆ្នាំ២០៣០ និង២០៥០។

ខ្ញុំសូមគាំទ្រចំពោះកម្មវិធីកំណែទម្រង់ វិធានការ និងអាទិភាព ដែលអង្គសន្និបាតបានដាក់ចេញតាមរយៈវេទិកាពិភាក្សាទាំង ៤ ដែលផ្តោតលើ អភិបាលកិច្ចអប់រំ ការកែទម្រង់សាលារៀន បរិវត្តកម្មអប់រំឧត្តមសិក្សា និងបរិយាកាសល្អសម្រាប់ការសិក្សាពេញមួយជីវិត ដោយឈរលើមូលដ្ឋាននៃសមិទ្ធផលនាពេលបច្ចុប្បន្ន និងកាលានុវត្តភាពថ្មីៗ, និងការកំណត់ទិសដៅកំណែទម្រង់ច្បាស់លាស់ ប្រកបដោយភាពជាក់ស្តែងនិយម ជាមួយនឹងគោលដៅជាក់លាក់, ព្រមទាំងមានរចនា

[illegible]ងមានយន្តការអនុវត្តច្បាស់លាស់ ដើម្បីកសាងមូលធនមនុស្សដែលមានសក្តា[illegible] ទាំងចំណេះដឹង ជំនាញ និងអាកប្បកិរិយា សម្រាប់ការអភិវឌ្ឍប្រទេសជាតិ។

រាជរដ្ឋាភិបាលកម្ពុជានឹងបន្តផ្តល់អាទិភាព ក្នុងការជ្រើសរើសគ្រូបង្រៀន ទាំងគ្រូបង្រៀនមានក្របខណ្ឌ និងគ្រូបង្រៀនកិច្ចសន្យាបច្ចេកទេស ដើម្បីបំពេញបន្ថែមនូវតម្រូវការគ្រូបង្រៀន និងប្រកបដោយគុណភាព, ការកៀរគរ និងការផ្តល់ធនធានបន្ថែមទៀតសម្រាប់គាំទ្រដល់ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន, ការអនុវត្តកំណែទម្រង់សាលារៀន, ការអភិវឌ្ឍ និងការលើកកម្ពស់បំណិនសតវត្សរ៍ទី២១ដល់យុវជន, ការអប់រំវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា, ការជំរុញការអប់រំឌីជីថល, កំណែទម្រង់សាលាគរុកោសល្យ, ការលើកកម្ពស់សុខភាពសិក្សា, និងការបង្កើតមជ្ឈមណ្ឌលឧត្តមភាពនៅគ្រឹះស្ថានឧត្តមសិក្សា។

ដើម្បីលើកទឹកចិត្ត និងយកចិត្តទុកដាក់លើកិច្ចការដ៏មានសារៈសំខាន់នេះ ខ្ញុំសូមផ្តល់អនុសាសន៍សំខាន់ៗសម្រាប់អនុវត្តបន្តដូចខាងក្រោមនេះ ៖

ទី១) បន្តពង្រឹងអភិបាលកិច្ចសាលារៀន និងអភិវឌ្ឍប្រព័ន្ធអប់រំឱ្យកាន់តែរឹងមាំ, មានភាពបុរេសកម្ម, ទំនើបកម្ម និងឆ្លើយតបទៅនឹងបរិការណ៍ជាតិ និងអន្តរជាតិ ដែលបាននិងកំពុងមានការប្រែប្រួលយ៉ាងឆាប់រហ័ស តាមរយៈការអនុវត្តស្តង់ដាសាលារៀនគំរូសាលារៀន គវអ. និងការធានាបាននូវសេវាអប់រំ ដែលមានប្រសិទ្ធភាព និងគុណភាពប្រកបដោយសមធម៌ បរិយាបន្ន ព្រមទាំងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។

ទី២) កំណែទម្រង់កម្មវិធីសិក្សា ដើម្បីបំពេញតម្រូវការនាពេលអនាគត ដោយធ្វើបច្ចុប្បន្នភាព និងធ្វើទំនើបកម្មកម្មវិធីសិក្សា ដើម្បីឱ្យឆ្លើយតបតម្រូវការទីផ្សារការងារនាពេលអនាគត រួមទាំងការគិតពិចារណា ការដោះស្រាយបញ្ហា ការច្នៃប្រឌិត និងការសហការរួមបញ្ចូលការអភិវឌ្ឍន៍ជំនាញទន់ ស្របទៅតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់អ្នកសិក្សា ដើម្បីឱ្យស្របគ្នាជាមួយបណ្តាប្រទេសជឿនលឿន។

ទី៣) រិះរកវិធីសាស្ត្របង្រៀន វិធីសាស្ត្ររៀន និងវិធីសាស្ត្រវាយតម្លៃថ្មី ដែលអាចអនុញ្ញាតឱ្យសិស្សអភិវឌ្ឍបំណិននៃការគិត ប្រកបដោយការត្រិះរិះពិចារណា ការដោះស្រាយបញ្ហាដែលទាក់ទងនឹងជីវិតប្រចាំថ្ងៃ, និងអនុវត្តចំណេះដឹងវិទ្យាសាស្ត្រក្នុងជីវិតប្រចាំថ្ងៃ។

ទី៤) ជំរុញការរៀនសូត្រពេញមួយជីវិត និងការអភិវឌ្ឍជំនាញ បង្កើតគំនិតផ្តួចផ្តើមដែលលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់មនុស្សពេញវ័យ ក្នុងការទទួលបានឱកាសសិក្សាជាបន្តបន្ទាប់ ដើម្បីរក្សាការប្រកួតប្រជែង និងសម្របខ្លួននៅក្នុងកម្លាំងការងារ។

ទី៥) បន្តកែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ដោយត្រូវលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនចេញថ្មី និងបន្តធ្វើក្រឹតការគ្រូបង្រៀន ឱ្យស្របតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន រួមទាំងការផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងផ្តល់ឧបករណ៍គាំទ្រចាំបាច់ ស្របតាមតម្រូវការក្នុងការអនុវត្តវិធីសាស្ត្របង្រៀនបែបថ្មី និងការអប់រំឌីជីថល។ គ្រូបង្រៀនគឺជាបេះដូងនៃប្រព័ន្ធអប់រំ ដូច្នេះតាមរយៈការពង្រឹងជំនាញរបស់គ្រូបង្រៀន យើងនឹងធានាបាននូវការអប់រំប្រកបដោយគុណភាព និងភាពច្នៃប្រឌិតថ្មី និងការផ្សារភ្ជាប់គំនិតច្នៃបង្កើតទាំងនោះទៅនឹងជីវភាពរស់នៅជាក់ស្តែង។

ទី៦) បន្តអភិវឌ្ឍការអប់រំឌីជីថល ដោយត្រូវបន្តធ្វើសមាហរណកម្មវិស័យបច្ចេកវិទ្យាឌីជីថលទៅក្នុងកម្មវិធីសិក្សាគ្រប់កម្រិត, បំពាក់បន្ទប់ពិសោធន៍ឌីជីថល, ភ្ជាប់បណ្តាញអគ្គិសនី និងអ៊ីនធើណិតនៅតាមគ្រឹះស្ថានសិក្សា, លើកកម្ពស់គុណវុឌ្ឍិនិងសមត្ថភាពឌីជីថលដល់គ្រូបង្រៀន, បញ្ចូលការប្រើប្រាស់បច្ចេកវិទ្យាទៅក្នុងការបង្រៀននិងរៀន, កែលម្អមាតិកាឌីជីថល និងបង្កើតមជ្ឈមណ្ឌលអប់រំឌីជីថល និងផ្សព្វផ្សាយវេទិកាឌីជីថល ឱ្យកាន់តែទូលំទូលាយ និងគ្រប់ជ្រុងជ្រោយ។

ទី៧) បន្តលើកកម្ពស់សុខភាពអនាម័យនៅតាមគ្រឹះស្ថានសិក្សា និងត្រៀមវិធានការឆ្លើយតបនិងចូលរួមទប់ស្កាត់ភ្លាមៗ ព្រមទាំងបង្កើនការអប់រំអំពីសុវត្ថិភាពសុខភាពសិក្សា, សុវត្ថិភាពចំណីអាហារ, កែលម្អហេដ្ឋារចនាសម្ព័ន្ធសុខភាព ដូចជា រៀបចំបន្ទប់សុខភាពស្តង់ដា, បរិស្ថានសាលារៀនបៃតង, សាលារៀនស្អាតគ្មានសំរាម, និងការលើកកម្ពស់ការប្រើប្រាស់ទឹកស្អាត និងអនាម័យ។ ការដោះស្រាយសុខភាពផ្លូវចិត្ត និងសុខុមាលភាពរបស់សិស្សានុសិស្សនៅក្នុងសាលារៀន រួមបញ្ចូលទាំងកម្មវិធីអប់រំសុខភាពផ្លូវចិត្ត និងសុខុមាលភាពនៅក្នុងសាលារៀន។ សាលារៀនត្រូវតែជាកន្លែងសុវត្ថិភាពដែលចិញ្ចឹមទាំងការសិក្សា និងការលូតលាស់ផ្លូវចិត្ត។

ទី៨) ជំរុញភាពជាដៃគូសាធារណៈ និងសហគមន៍ក្នុងការអប់រំ ដោយចាប់ផ្តើមអនុវត្តនៅតាមសាលារៀនគំរូ និងសាលារៀនគោលដៅ គវអ. ដោយត្រូវបន្តធ្វើសុខដុមនីយកម្ម

និងរៀបចំសេចក្តីណែនាំអនុវត្តឱ្យបានគ្រប់ជ្រុងជ្រោយ ព្រមទាំងផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងបំផុសស្មារតីចូលរួមតាមគោលការណ៍ស្ម័គ្រចិត្ត សម្រាប់គាំទ្រដល់ការបន្ថែមមុខវិជ្ជាថ្មីៗ ឬការបន្ថែមម៉ោងអនុវត្ត ដើម្បីឱ្យសិស្សចំណាយពេលវេលាកាន់តែច្រើននៅក្នុងសាលារៀន ក្រោមការគ្រប់គ្រង និងដឹកនាំរបស់គ្រូបង្រៀន។ ការបង្កើតទំនាក់ទំនងល្អរវាងមាតាបិតាសិស្ស និងគ្រូបង្រៀន ដើម្បីផ្តល់ព័ត៌មាន និងជួយគ្នាទៅវិញទៅមកអំពីការអប់រំសិស្ស, និងការអប់រំមាតាបិតាឱ្យផ្តល់តម្លៃបន្ថែមទៀតដល់ការអប់រំ និងលើកទឹកចិត្តពួកគាត់ឱ្យចូលរួមជាមួយការសិក្សារបស់កូនកាន់តែច្រើន។

ទី៩) បន្តអភិវឌ្ឍកុមារ និងយុវជន ឱ្យមានស្មារតីទទួលខុសត្រូវ មានជំនឿលើសមត្ថភាពរបស់ខ្លួន និងប្រកាន់ខ្ជាប់នូវទង្វើវិជ្ជមានក្នុងសង្គម មានសីលធម៌ និងការរស់នៅក្នុងភាពជាពលរដ្ឋល្អ តាមរយៈការបំផុសចលនា "កូនល្អ សិស្សល្អ មិត្តល្អ ពលរដ្ឋល្អ", កម្មវិធីយុវជនស្ម័គ្រចិត្ត, និងការលើកទឹកចិត្តឱ្យយុវជនចុះជួយដល់មូលដ្ឋាននៅតាមសហគមន៍, ព្រមទាំងបន្តបណ្តុះបណ្តាលជំនាញបច្ចេកទេស និងជំនាញទន់ដល់យុវជន សំដៅឆ្លើយតបបានទៅនឹងឱកាសការងារ និងភាពរឹងមាំនៃកោសិកាសង្គម។

ទី១០) បន្តលើកកម្ពស់វិស័យកីឡា ដើម្បីកសាងមនុស្សគ្រប់រូបឱ្យមានសុខភាព និងសុខុមាលភាពល្អ, កាយសម្បទាមាំមួន, ឆន្ទៈមោះមុត, អំណត់ព្យាយាម, មានវិន័យ, មានស្មារតីក្រុម, គំនិតច្នៃប្រឌិត, និងមានការតស៊ូស្វិតស្វាញ។ ជាមួយនេះ ពង្រឹងការគ្រប់គ្រងវិស័យអប់រំកាយ និងកីឡា, ពង្រឹងយន្តការ ដែលមានស្រាប់រួមទាំងសហព័ន្ធកីឡា ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកីឡា ការបណ្តុះបណ្តាលធនធានមនុស្ស និងការលើកទឹកចិត្ត ដែលជាកត្តាចម្បងក្នុងការបង្កើនប្រសិទ្ធភាព និងគុណភាពនៃការត្រៀមខ្លួនរបស់អត្តពលិក, និងការពង្រឹងគុណភាពនៃការប្រកួតកីឡាគ្រប់កម្រិត។

ទី១១) បន្តការលើកកម្ពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ, ការងារគោលនយោបាយ និងផែនការអប់រំ រួមទាំងផែនការនៅកម្រិតមន្ទីរអប់រំ យុវជន និងកីឡា និងផែនការសាលារៀន ឆ្ពោះទៅដោះស្រាយបញ្ហារបស់សាលារៀន ឱ្យបានពេញលេញ និងប្រទាក់ក្រឡាគ្នា។

ទី១២) លើកកម្ពស់ការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈនិងគណិតវិទ្យានៅគ្រប់កម្រិត ដើម្បីរៀបចំសិស្ស និងនិស្សិតឱ្យកាន់តែប្រសើរឡើង និងទទួលបាននូវបំណិនសតវត្សទី ២១ ជាពិសេសជំរុញការបំពាក់បំប៉នជំនាញ និងបច្ចេកវិទ្យា ដែលជា

តម្រូវការទីផ្សារការងារ និង ធុរកិច្ច; ពង្រឹងការបណ្តុះបណ្តាល និង ការផ្លាស់ប្តូរជំនាញស្របនឹងតម្រូវការទីផ្សារការងារ។

ទី១៣) ពង្រឹងគុណភាពនៅឧត្តមសិក្សា ដើម្បីបង្កើតមូលធនមនុស្ស បញ្ញាជាតិ និងឃ្លាំងពុទ្ធិសកល ដោយយកចិត្តទុកដាក់លើជីវភាពគ្រូបង្រៀន, បុគ្គលិកសិក្សា និង សាស្ត្រាចារ្យ ផ្តល់អាហារូបករណ៍ រៀបកម្មវិធីណែនាំ និងបង្កើតភាពជាដៃគូជាមួយឧស្សាហកម្មនានា ដើម្បីបំផុស និងរក្សាសិស្សក្នុងវិស័យសំខាន់ៗទាំងនេះ។

ទី១៤) ពង្រឹងការអប់រំបច្ចេកទេស និងដាក់ឱ្យអនុវត្ត "គន្លងអប់រំ" ដែលមានបីប្រភេទគឺ គន្លងវិទ្យាសាស្ត្រពិត គន្លងវិទ្យាសាស្ត្រសង្គម និងគន្លងអប់រំវិជ្ជាជីវៈ នៅតាមសាលារៀនដែលមានទីតាំងប្រកបដោយសក្តានុពល ដើម្បីផ្តល់ឱ្យសិស្សានុសិស្ស និងយុវជននូវមាគ៌ាផ្សេងៗគ្នាទៅកាន់អាជីពជោគជ័យ។ លើកកម្ពស់កម្មសិក្សាកម្រិតជាតិ និងអន្តរជាតិ តាមរយៈកិច្ចសហប្រតិបត្តិការជាមួយឧស្សាហកម្ម ដើម្បីធានាថាកម្មវិធីទាំងនេះបំពេញតម្រូវការទីផ្សារការងារ និងផ្តល់ដល់យុវជននូវចំណេះដឹង និងជំនាញច្បាស់លាស់។

ខ្ញុំមានសុទិដ្ឋិនិយមចំពោះសមិទ្ធផលរបស់អង្គសន្និបាត និងអនុសាសន៍សំខាន់ៗ ដែលខ្ញុំបានលើកឡើងនាពេលនេះ ដែលនឹងក្លាយជាមូលដ្ឋាន និងជាធាតុចូលសម្រាប់យកទៅអនុវត្តក្នុងវិស័យអប់រំកម្ពុជានៅឆ្នាំសិក្សាថ្មី និងឆ្នាំសិក្សាបន្តបន្ទាប់។

នៅទីបញ្ចប់ ជាមួយនឹងការប្រកាសបិទ **«សន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០២៣-២០២៤ និងលើកទិសដៅការងារឆ្នាំសិក្សា ២០២៤-២០២៥»** ខ្ញុំសូមជូនពរឯកឧត្តម លោកជំទាវ លោក លោកស្រី បុគ្គលិកអប់រំ លោកគ្រូ អ្នកគ្រូ និងអង្គសន្និបាតទាំងមូល សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**